ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

**គោរពជូន**
**ឯកឧត្តម ហ៊ុន ម៉ានិត អគ្គនាយក នៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច**
**នៃក្រសួងការពារជាតិ**

ឯកឧត្តម ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ!

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរប្រកបដោយទឹកចិត្តសប្បាយរីករាយក្រៃលែង ក្នុងឱកាសដែល **ឯកឧត្តម ហ៊ុន ម៉ានិត** អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច នៃក្រសួងការពារជាតិ ត្រូវបានរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ផ្តល់សេចក្តីទុកចិត្តតែងតាំងជា **"មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងគោក"** បន្ថែមលើមុខងារបច្ចុប្បន្ន។

ការតែងតាំងមុខតំណែងបន្ថែមជា **"មេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងគោក"** នេះពិតជាស័ក្តិសមទៅនឹងសមត្ថភាព ស្នាដៃ ចំណេះដឹង គុណធម៌ និងការលះបង់កម្លាំងកាយចិត្តយ៉ាងធំធេងក្នុងបុព្វហេតុជាតិរបស់ **ឯកឧត្តម** ដែលបានចូលរួមចំណែករក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា បម្រើឱ្យការរីកចម្រើនរបស់សង្គមជាតិ ក៏ដូចជាសុកមង្គលនិងភាពសុខដុមរមនារបស់ប្រជាជាតិខ្មែរទាំងមូល។

ដោយសារទឹកចិត្តនិងកាយវិការស្នេហាមាតុភូមិរបស់ **ឯកឧត្តម** នៅគ្រប់កាលៈទេសៈ យើងខ្ញុំទាំងអស់គ្នាប្តេជ្ញាគាំទ្រឥតងាករេនៅគ្រប់កាលៈទេសៈទាំងអស់ ក្នុងឆន្ទៈដ៏មោះមុតជាមួយ **ឯកឧត្តម** ដើម្បីចូលរួមរក្សាឱ្យបានជាដាច់ខាតនូវសន្តិភាព វិបុលភាព និងសេចក្តីសុខក្សេមក្សាន្តជាដរាបរបស់ជាតិនិងប្រជាជនកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយថែរក្សា ការពារ **ឯកឧត្តម** និង **លោកជំទាវ** ព្រមទាំង **បុត្រា បុត្រី** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ព្រមទាំងទទួលបានសព្វសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសមប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ហ៊ុន ម៉ានិត** អគ្គនាយក នៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច និងជាមេបញ្ជាការរង បញ្ជាការដ្ឋានកងទ័ពជើងគោក នៃក្រសួងការពារជាតិទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃអង្គារ ១៤ រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ខែ មីនា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh